# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ រុន វ៉ាន់ ភេទប្រុស អាយុ៥៩ឆ្នាំ
## រស់នៅភូមិកោះកេរ្ដិ៍ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ
## មុខងារសម័យខ្មែរក្រហមៈ យុទ្ធជនកងចល័ត
## ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៣
## សម្ភាសន៍ដោយៈ ឡុង ដានី
## ០០:៤១:៣១
## ២៤ទំព័រ

ដានីៈ មុននឹងខ្ញុំសួរនាំលោកពូ ខ្ញុំចង់ណែនាំខ្លួនខ្ញុំប្រាប់លោកពូ ខ្ញុំឈ្មោះដានី ហើយបងនោះគាត់ឈ្មោះវណ្ណៈ ពួកខ្ញុំពីរនាក់នេះមកពីមជ្ឈមណ្ឌលឯកសារកម្ពុជានៅទីក្រុងភ្នំពេញ ហើយខ្ញុំមកដល់ស្រុកភូមិលោកពូនេះ គឺចង់ដឹងពីការរស់នៅរបស់បងប្អូនប្រជាពលរដ្ឋយើងដូចអ៊ំ ពូមីង រស់ក្នុងភូមិយើង ដូចថាឆ្លងកាត់តាំងពីតូចមក សម័យសង្គ្រាម សម័យ៣ឆ្នាំក្រោយមក បន្ទាប់ពីឆ្នាំ៧៩មក ជីវិតឆ្លងកាត់យ៉ាងម៉េច រហូតមកដល់សម័យរាជរដ្ឋាភិបាលយើងអភិវឌ្ឍន៍អីយ៉ាងម៉េច ហើយមានការប៉ះពាល់ខាងដូចថាការអភិវឌ្ឍន៍ ការអភិរក្សប្រាសាទទៅវាប៉ះពាល់យ៉ាងម៉េចខ្លះ ។ អីចឹងលោកពូមានអីឆ្ងល់ចង់សួរនាំខ្ញុំទេ?

វ៉ាន់ៈ មិនឆ្ងល់ត្រង់ណាទេ ។

ដានីៈ អីចឹងខ្ញុំចាប់ផ្ដើម ដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ លោកពូឈ្មោះអីដែរ?

វ៉ាន់ៈ រុន វ៉ាន់ ។

ដានីៈ អាយុប៉ុន្មានហើយសព្វថ្ងៃ?

វ៉ាន់ៈ ហាជាង ។

ដានីៈ ហាប៉ុន្មាន?

វ៉ាន់ៈ ៥៤ ។

ដានីៈ កើតឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានដែរ?

វ៉ាន់ៈ ១៩៥៤ ។

ដានីៈ ឆ្នាំ១៩៥៤?

វ៉ាន់ៈ ខុសបាទ ។

ដានីៈ បាទ?

វ៉ាន់ៈ បាទ អីចុះឯង អេ៎! ខុសហើយដឹង ប៉ុណ្ណេះឯង១៩៥៤ដាក់ក្នុងអត្តសញ្ញាណបណ្ណ ។

ដានីៈ ក្នុងអត្តសញ្ញាណបណ្ណ១៩៥៤?

ភ៉ន់៖ បាទ ។

ដានី៖ អ៊ីចឹងអាយុជិតហុកហើយ?

ភ៉ន់៖ ជិតហុកបាត់ហើយបានត្រូវ ដាក់វិញទៅ ។

ដានី៖ ៥៩-៦០ហើយ ។

ភ៉ន់៖ បាទ ៦០ហើយ ។

ដានី៖ ឥឡូវ២០១៣ហើយ ។

ភ៉ន់៖ ២០១៣ហើយ ៦០ហើយ ។

ដានី៖ ៥៩មិនមែន៥៨ទេ ។

ភ៉ន់៖ បាទ ៥៩ ។

ដានី៖ គ្រួសារលោកពូគាត់ឈ្មោះអីដែរ?

ភ៉ន់៖ ឈ្លោក យុន ។

ដានី៖ ឈ្លោក យុន?

ភ៉ន់៖ បាទ ។

ដានី៖ ឈ្លោក «យ» «ុ» និង «ន» ។

ភ៉ន់៖ បាទ ។

ដានី៖ គាត់អាយុប៉ុន្មានដែរ?

ភ៉ន់៖ ហាសាម ។

ដានី៖ អាយុប្អូនលោកពូច្រើន?

ភ៉ន់៖ ប្អូន សាម-សែហើយឆ្នាំរកានោះ មិនបានមើលអត្តសញ្ញាណបណ្ណវា អាយុសែហើយ ។

ដានី៖ សែជាងនេះ?

ភ៉ន់៖ បាទ ។

ដានី៖ ឆ្នាំរកា?

ភ៉ន់៖ សែជាងព្រោះកើត ។

ដានី៖ លោកពូមានកូនចៅប៉ុន្មាននាក់?

ភ៉ន់៖ កូនវា៧នាក់ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភ៉ន់៖ ស្រី៤ ប្រុស២ ៦នាក់ទេលោកប្អូន ។

ដានី៖ ៦នាក់ មិនមែន៧ទេ ។

ភ៉ន់៖ ច្រលំ ។

ដានី៖ លោកតាស្រុកកំណើតជានៅភូមិ-ឃុំ ស្រុកអី?

ភ៉ន់៖ ភូមិកោះកេរ្តិ៍ ឃុំស្រយ៉ង់ ។

ដានី៖ ស្រុកកំណើតតែម្តង?

ភ៉ន់៖ ស្រុកកំណើតកោះកេរ្តិ៍ កំណើតកើតនៅនេះ ។

ដានី៖ កំណើតនៅភូមិ?

ភ៉ន់៖ កោះកេរ្តិ៍ ។

ដានី៖ ភូមិកោះកេរ្តិ៍ ពីដើមមកគេហៅអីចឹងដែរ?

ភ៉ន់៖ បាទ កោះកេរ្តិ៍ ។

ដានី៖ ពីដើមមកឃុំ?

ភ៉ន់៖ ឃុំស្រយ៉ង់ដែរ ។

ដានី៖ ស្រុកអី?

ភ៉ន់៖ ស្រុកគូលែន ខេត្តព្រះវិហារ ។

ដានី៖ ស្រុកគូលែន ខេត្តព្រះវិហារ ។

ភ៉ន់៖ បាទ ។

ដានី៖ ចុះសព្វថ្ងៃនេះរស់នៅភូមិអីដែរសព្វថ្ងៃ?

ភ៉ន់៖ កោះកេរ្តិ៍ហ្នឹងដែរ ។

ដានី៖ សព្វថ្ងៃនៅភូមិកោះកេរ្តិ៍ដដែរ?

ភ៉ន់៖ បាទ ។

ដានី៖ ឪពុកម្តាយលោកតាគាត់ស្រុកកំណើតនៅភូមិកោះកេរ្តិ៍ហ្នឹងដែរ?

ភ៉ន់៖ កោះកេរ្តិ៍ដែរ ។

ដានី៖ គាត់ឈ្មោះអីដែរ ឪពុកលោកតា?

ភ៉ន់៖ រុន ។

ដានី៖ គាត់ឈ្មោះ រុន?

ភ៉ន់៖ បាទ ។

ដានី៖ ត្រកូលអីដែលត្រកូលគាត់?

ភ៉ន់៖ ស្រី រុន ។

ដានី៖ ស្រី រុន?

ភ័ន់ៈ បាទ ។

ដានីៈ ចុះម្ដាយ?

ភ័ន់ៈ ទុំ គាំ ។

ដានីៈ ខ្ញុំ គាំ?

ភ័ន់ៈ បាទ ស្លាប់អស់ហើយ ។

ដានីៈ ស្លាប់តាំងពីអន្កាល់?

ភ័ន់ៈ ឪពុកខ្ញុំស្លាប់ខែ៣ ខែ២ ម្ដាយយូរហើយ ។

ដានីៈ ស្លាប់អស់ហើយនេះ ឪពុកស្លាប់ខែ៣នេះទេ?

ភ័ន់ៈ បាទ ។

ដានីៈ ហើយម្ដាយស្លាប់យូរហើយ?

ភ័ន់ៈ យូរហើយ ។

ដានីៈ ហើយមានបងប្អូនប៉ុន្មាននាក់?

ភ័ន់ៈ បងប្អូនខ្ញុំវា និយាយពីនៅរស់ទេលោកគ្រូ ។

ដានីៈ ទាំងអស់តែម្ដងប៉ុន្មាននាក់?

ភ័ន់ៈ មើលរាប់សិន ២ ប្រុស៤ ស្រី២ ។

ដានីៈ ប្រុស៤ ស្រី២?

ភ័ន់ៈ បាទ ប្អូនបង្កើត បងបង្កើត ពោះមួយ ។

ដានីៈ ប្រុស៤ ស្រី២ លោកពូកូនទីប៉ុន្មាន?

ភ័ន់ៈ កូនទី២ ។

ដានីៈ លោកពូកាលពីក្មេងៗបានរៀនសូត្រអីដល់ណាដែរ?

ភ័ន់ៈ ទៅបួស ។

ដានីៈ ទៅបួសនៅវត្តណា?

ភ័ន់ៈ វត្តស្រយ៉ង់ ។

ដានីៈ បួសបានប៉ុន្មានវស្សាដែរ?

ភ័ន់ៈ បាន២ រដ្ឋប្រហារបណ្ដោយ ។

ដានីៈ ២ឆ្នាំរដ្ឋប្រហារ?

ភ័ន់ៈ បាទ ។

ដានីៈ រដ្ឋប្រហារមកធ្វើអីទៀត?

ភ៉ន់៖ ឈប់បួសមកបង្ហាត់កូនក្មេង កុមារ ។

ដានី៖ បង្ហាត់ក្មេងបានប៉ុន្មានឆ្នាំ?

ភ៉ន់៖ បានយូរគ្រាន់ដែរ មើលយូរហើយ៣-៤ឆ្នាំដែរ ។

ដានី៖ ដល់ឆ្នាំណា?

ភ៉ន់៖ ចាប់ឆ្នាំគេកាយចំណាប់ ។

ដានី៖ ដល់ពេលខ្មែរក្រហមចូល?

ភ៉ន់៖ បាទ ខ្មែរក្រហមចូលហើយ បាយរួមអស់ហើយ ។

ដានី៖ ដល់ឆ្នាំខ្មែរក្រហមចូលឈប់បង្ហាត់ហើយ?

ភ៉ន់៖ បាទ ។

ដានី៖ អីចឹងបួសបាន២ឆ្នាំដល់រដ្ឋប្រហារ ហើយចាប់ផ្តើមបង្ហាត់ក្មេង បង្ហាត់ក្មេងរហូតទៅដល់ខ្មែរក្រហមចូលភូមិ បាយរួមហ្នឹងឈប់ ។

ភ៉ន់៖ ឈប់ ។

ដានី៖ ដល់ឈប់ទៅធ្វើអីទៀតទៅ?

ភ៉ន់៖ ធ្វើស្រែចំការ ។

ដានី៖ ឈប់ទៅ?

ភ៉ន់៖ ធ្វើស្រែភូមិនេះ ។

ដានី៖ ធ្វើស្រែនៅតាមផ្ទះឬយ៉ាងម៉េច?

ភ៉ន់៖ ធ្វើស្រែនៅតាមផ្ទះបេះ ។

ដានី៖ កាលជំនាន់ពួកខ្មែរក្រហមមកគេអត់ដាក់ឲ្យយើងបាយរួមទេ?

ភ៉ន់៖ បាយរួម ដល់បាយរួមគេធ្វើស្រែរួម ដល់ឈប់ពីបាយរួមបែកបាក់ វៀតណាមថយទៅនោះវិញយើងធ្វើស្រែតាមម្ចាស់ៗវិញបេះ ។

ដានី៖ អីចឹងកាលពីជំនាន់៣ឆ្នាំ នៅស្រុកភូមិយើងយ៉ាងម៉េចដែរ លំបាកឬស្រួល?

ភ៉ន់៖ លំបាកណាស់លោកក្មួយអើយ វេទនាណាស់ ហៅបែកស្រុក បែកស្រែនោះ ៨៣បែកស្រុក ភូមិនេះបែក ។

ដានី៖ អត់ទេ ខ្ញុំចង់ដឹងពី៧៥-៧៩ សម័យពួកគេធ្វើសហករណ៍?

ភ៉ន់៖ លំបាកណាស់បាយបបរ ទឹកខ្ទុកៗ ។

ដានី៖ បាយបបរ ទឹកខ្ទុកៗ?

ភ៉ន់៖ ប៉ះណាវៃដួងម៉ឺងទៅអត់ក៏មាន បានតែប៉ុណ្ណោះទេហូបនៅភូមិនេះ ។

ដានី: នៅភូមិនេះ?

ភ៉ន់: បាទ កម្មណាស់ ។

ដានី: កាលហ្នឹងប្រជាជនរស់នៅហ្នឹង ហើយមានប្រជាជន១៧មេសា មកដែរ?

ភ៉ន់: មកនៅនេះដែរ ។

ដានី: ហើយភូមិហ្នឹងគេមានតែមួយភូមិ ឬមានប៉ុន្មានភូមិកាលជំនាន់ប៉ាយរូម?

ភ៉ន់: ប៉ាយរូមភូមិនេះមួយ នៅភូមិរំចេកមួយ ។

ដានី: គេបំបែកភូមិឬយ៉ាងម៉េច?

ភ៉ន់: វាបំបែក គេយកពីអ្នកនោះមក អ្នកនេះដងចំរុះ សព្វថ្ងៃនៅចំរុះគ្នាអ្នកភូមិរំចេក បើនេះ អ្នកកោះកេរ្តិ៍សុទ្ធ ។

ដានី: នេះអ្នកកោះកេរ្តិ៍សុទ្ធ បើរំចេកចំរុះ?

ភ៉ន់: ចំរុះ ចូលពីនេះពីនោះផង តែអ្នកកោះកេរ្តិ៍ខ្លះដើមកំណើត ។

ដានី: កាលហ្នឹងលោកពូធ្វើស្រែ?

ភ៉ន់: ស្រែ ។

ដានី: អត់មានធ្វើអីទេ?

ភ៉ន់: អត់ទេ ។

ដានី: ធ្វើស្រែរហូត?

ភ៉ន់: រហូត ។

ដានី: ចុះអ្នកដែលគេមកគ្រប់គ្រងដូចពួកខ្មែរក្រហមកាលជំនាន់៣ឆ្នាំមកគ្រប់គ្រង គេមកពីណា?

ភ៉ន់: មិនដឹងមកពីខាងណាទេ មកពីណាណី មិនហ៊ានសួរគេណា ។

ដានី: អត់សួរហ៊ាន?

ភ៉ន់: ស្មានហ្នឹងមិនហ៊ានទេ សុទ្ធមិត្តបង មិត្តប្អូនអស់រលីង ។

ដានី: មិត្តបង មិត្តប្អូន?

ភ៉ន់: ហ្នឹងហើយ ខ្ញុំថាងាប់ហើយចេះ ដំណាំដាំដុះគេអត់ឲ្យហូបទៀតនោះម្ចាស់ផ្ទះដាំ អត់ឲ្យកាប់ ហូបចេកអី ។

ដានី: កាលហ្នឹងគេមានចាប់មនុស្សសម្លាប់ដែរ?

ភ៉ន់: ភូមិនេះអត់សូវមានប៉ុន្មានទេ ស្លាប់តិចណាស់ ស្លាប់ដោយសារស្មានទោសដូចថាចាប់ដាក់គុក ទេ មួយហ៊ីអានោះវៀតណាមដើរទេ មិនទាន់ខ្មែរក្រហមដាច់ទេ និយាយពីចុះវិញ មួយហ៊ី ហ្នឹងមកដល់គេបានចាប់ខុស ក៏ប៉ុណ្ណោះឯង ដល់ខ្មែរក្រហមសម្លាប់ខ្លះដែរ អ្នកបងប្អូន១៧

នោះដែលថាខុសគ្រូវាអត់ជំនឿ ពួកហ្នឹងដែលចេះជំនឿ គ្នាខុសអីដូចឡប់ឡែ ក៏ចាប់បាញ់ចោល ។

ដានី: ខ្មែរក្រហម?

ភ័ន់: បាទ ថាសតិអារម្មណ៍ ។

ដានី: ថាសតិអារម្មណ៍?

ភ័ន់: សម័យហ្នឹងតែប៉ុណ្ណោះឯង ឈឺអីគ្រុនល្មមៗក៏វាថា ។

ដានី: តែអ្នកធ្វើប្រធានៗ គេមកពីឆ្ងាយៗ?

ភ័ន់: ឆ្ងាយៗ ។

ដានី: អត់ដែលស្គាល់គេទេ?

ភ័ន់: មិនស្គាល់គេទេ អ្នកឆ្ងាយដូចគេគណៈស្រុកម៉េចស្គាល់ ឃុំៗពីដើមគេនៅពីសម័យក្រហម គេធ្វើឃុំ ទាហានឃុំ យោធាឃុំ គេនៅកាន់កាប់ ធ្វើទាហាន៨ណាត់ ពីដើមប្រធានឃុំ ។

ដានី: អីចឹងភូមិរំចេកគេទើបតែបង្កើតថ្មីក្រោយពេលពួកខ្មែរក្រហមចូលមក?

ភ័ន់: ក្រោយទេ ។

ដានី: ចូលមកភូមិរំចេកមានអ្នកភូមិកោះកេរ្តិ៍ខ្លះ អ្នក១៧មេសា?

ភ័ន់: អត់ទេ អ្នក១៧ មេសា ដល់វៀតណាមថយ៧៩ទៅវិញ គេថយទៅភូមិគេអស់ ។

ដានី: ទៅស្រុកគេ?

ភ័ន់: ទៅស្រុកគេអស់ មិនដឹងទៅណា ទៅណី ទៅស្រុកស្រែខ្លះ ខ្លះបានមកជួបឥឡូវៗក៏មានមកលេង ដែលគេបានរស់នេះ អត់មានកើតអីមកសួរដែរ តែវេទនា ដូចយើងអ្នកស្រុកកំណើតកើតនេះដែរ ត្រដាបត្រដួសចេះឯង អត់បាយអត់ទឹកចុះឯង ឲ្យថាវានេះអត់ទេ ។

ដានី: អីចឹងជំនាន់ពាឆ្នាំហ្នឹង ធ្វើស្រែ ធ្វើចំការរួម ហូបបបររួម?

ភ័ន់: បបរ ។

ដានី: ហូបបបរប៉ុន្មានពេលមួយថ្ងៃ?

ភ័ន់: បបរព្រឹក ល្ងាច ។

ដានី: ព្រឹក ល្ងាច?

ភ័ន់: ព្រឹកចេះបបរ ល្ងាចក៏បបរប៉ុណ្ណោះឯង គ្មានអីទេ បើស្រូវខ្ញុំកោតដូចថាស្មាទោសស្រូវប៉ុណ្ណោះៗជជ្រុកដាក់បើសៗវាអត់ឲ្យហូបបាយមិនដឹងយ៉ាងម៉េច ។

ដានី: អត់ឲ្យហូបបាយ?

ភ៉ន់: នោះហើយ មិនដឹងយ៉ាងម៉េច ខ្ញុំថាស្រេចហើយបាយស្រូវឡើងច្រើនធ្វើបានស្រុកនេះ ក្នុងភូមិ តែអត់ឲ្យហូបបាយ ឲ្យតែបបរ ។

ដានី: គេយកស្រូវទៅណាទៅអីចឹង?

ភ៉ន់: ស្រូវប៉ះត្រង់ណាឃើញគេមកដឹក អ្នកស្រុកណាណី អ្នកភូមិណាណី អង្គការគេមកដឹកយក ទៅឲ្យអ្នកនេះ ឲ្យអ្នកនោះ មិនដឹងដឹកឲ្យអ្នកណា ថាឲ្យគេនោះអត់ ។

ដានី: អីចឹងគេមកដឹកយកទៅស្រូវអី?

ភ៉ន់: ដឹក ។

ដានី: ប្រជាជនគេឲ្យហូបបបរ?

ភ៉ន់: ឲ្យហូបបបរ ។

ដានី: អត់មានពីណាតវ៉ាទាមទារអី?

ភ៉ន់: អត់ហ៊ានទេ ។

ដានី: អត់ហ៊ានទេ?

ភ៉ន់: ហ៊ានម៉េចស្រេច ។

ដានី: ហ៊ានគេសំរេចម៉េច?

ភ៉ន់: សម្លាប់ចោល អត់ហ៊ានតវ៉ាទេសម័យនោះ ។

ដានី: ប៉ុន្តែលោកពូថាគេអត់ដែលឃើញគេសម្លាប់?

ភ៉ន់: អត់ហ៊ានមាត់ បើសម្លាប់ក៏មិនច្រើននៅនេះ ។

ដានី: មានសម្លាប់ដែរតែមិនច្រើន?

ភ៉ន់: បាទ ។

ដានី: ប៉ុន្មាននាក់?

ភ៉ន់: ក្នុងភូមិនេះខ្ញុំថាឃើញច្បាស់នឹងភ្នែក១នាក់ទេ ២-៣នាក់ទេ យកទៅសម្លាប់ចោលកន្លែង ផ្ទះនោះ ។

ដានី: កន្លែងផ្ទះនោះ?

ភ៉ន់: បាទ ។

ដានី: សម្លាប់រឿងអីហ្នឹង?

ភ៉ន់: ដែលថាខុសគ្រូ ម្យ៉ាងក៏ឃើញបងប្អូនយើងទាហានដែលបែកបាក់មួយហ៊ីកនោះគ្មានរត់មក ក៏ស្កាំងស្គម ក៏ឲ្យនៅ តែសម្លាប់២នាក់នៅប្រាសាទ ។

ដានី: ឈ្មោះអីទៅអ្នកដែលគេសម្លាប់?

ភ៉ន់៖ អត់ស្គាល់ទេ ។

ដានី៖ អត់ស្គាល់ឈ្មោះ?

ភ៉ន់៖ បាទ ។

ដានី៖ តែអ្នកប្រធានខាងខ្មែរក្រហមឈ្មោះអីទៅ?

ភ៉ន់៖ បាត់ទៅណាអស់ហើយ អត់មានស្គាល់គេទេ ។

ដានី៖ អត់ស្គាល់ឈ្មោះគាត់ទេ?

ភ៉ន់៖ មិនមែនអ្នកភូមិនេះទេ អ្នកឆ្ងាយៗគេមកធ្វើការ អ្នកភូមិនេះគេឲ្យធ្វើក្រុមអីតិចតួច ។

ដានី៖ កាលជំនាន់ហ្នឹងលោកពូមានប្រពន្ធនៅ?

ភ៉ន់៖ មានហើយ ។

ដានី៖ ការតាំងពីឆ្នាំណា?

ភ៉ន់៖ភ្លេចបាត់ហើយ ។

ដានី៖ ការកំពុងតែបង្ហាត់កូនក្មេង ឬការក្រោយ?

ភ៉ន់៖ បង្ហាត់ ។

ដានី៖ ពេលបង្ហាត់កូនក្មេងចន្លោះពី៧០-៧៥?

ភ៉ន់៖ បាទ ។

ដានី៖ ហើយការពេលហ្នឹងទៅ ។ កាលជំនាន់៣ឆ្នាំហ្នឹងធ្វើតែស្រែទេ?

ភ៉ន់៖ ធ្វើស្រែ ។

ដានី៖ ធ្វើស្រែរហូត?

ភ៉ន់៖ ស្រែរួមគ្នា ។

ដានី៖ ធ្វើរួមគ្នា ។

ភ៉ន់៖ បាទ ។

ដានី៖ អ្នកជម្លៀសគេជម្លៀសមកពីណាមក?

ភ៉ន់៖ អ្នកភ្នំពេញ អ្នកអីណាគេខ្លះ ។

ដានី៖ មកពីភ្នំពេញ?

ភ៉ន់៖ បាទ ភ្នំពេញខ្លះ ណាខ្លះចំរុះគ្នា ពីណាតប់ពីណីទេ ។

ដានី៖ មកធ្វើស្រែជាមួយគ្នា ឬគេធ្វើបាបជាងអ្នកមូលដ្ឋាន?

ភ៉ន់៖ ដូចគ្នា លំបាកដូចតែគ្នា មិនថាអ្នកជំនាញ ឬអ្នកមិនជំនាញទេ ធ្វើបាបពពាក់ពពូនតែទាំងអស់គ្នា ស្ទូងស្រែក្រវនេះទាំងអស់គ្នា ផ្ទះនៅតាមរៀងខ្លួនចេះ ។

ដានី: ក្រេវ មេ៉ច?

ភ៉ន់: មកស្ទូងស្រូវ ដូចថាចុះស្រែមក នាំគ្នាមកទាំងអស់គ្នា ដាក់នេះ។

ដានី: មកច្រើនគ្នា មកជុំគ្នា ទាំងអ្នកចាស់ អ្នកថ្មី?

ភ៉ន់: ទាំងចាស់ ទាំងថ្មី។

ដានី: ហើយអ្នក១៧ មេសា ក៏អត់មានស្លាប់ដែរ?

ភ៉ន់: អត់ទេ ស្លាប់ដោយឈឺ ស៊ូដែរនៅនេះ កម្មវាអត់ឲ្យបាយស៊ី ឲ្យស៊ីតែបបរ ឈឺគ្រុនរងារធម្មតា។

ដានី: គ្រុនចាញ់?

ភ៉ន់: បាទ។

ដានី: នេះគ្រុនចាញ់ដែរ?

ភ៉ន់: បាទ។

ដានី: អីចឹងអ្នក១៧ មេសា ឈឺគ្រុនចាញ់ច្រើនទេ?

ភ៉ន់: ស្លាប់២នាក់ចាស់ៗ ដល់ពេលទៅវិញអស់ វៀតណាមដកថយថាចប់ហើយ ទៅស្រុករៀងខ្លួន។

ដានី: ពេលដែលខ្មែរក្រហមរត់អស់?

ភ៉ន់: អស់ហើយ ទៅភូមិគេ ស្រុកគេអស់។

ដានី: នៅសល់តែអ្នកស្រុកភូមិចាស់ៗ?

ភ៉ន់: នៅតែអ្នកចាស់ៗ។

ដានី: ពេលដែលចាស់ៗទៅ រំចេកនៅតែមានភូមិរំចេកអីចឹងដែរ?

ភ៉ន់: ភូមិរំចេក។

ដានី: គេអត់មកវិញទេ?

ភ៉ន់: អត់មក គេនៅហ្នឹងដដែល នេះក៏នៅនេះ។

ដានី: កាលពីមុនអត់មានគេរំចេក នៅនេះទាំងអស់?

ភ៉ន់: នៅនេះទាំងអស់ កាលពីកើតខ្ញុំទល់ប៉ុណ្ណេះឯងមក នៅនេះទាំងអស់ ពីយាយពីតា ម៉ែឪខ្ញុំនៅទាំងអស់ មិនកើតបួន កើតផ្លូវទេ នៅផ្ទះប្រប៉ុណ្ណេះ។

ដានី: កាលហ្នឹងប្រជាជនច្រើនទេ?

ភ៉ន់: ច្រើនគ្រាន់ បំបែកទៅនោះបានទៀតខ្លះ នៅតាមផ្លូវ ខ្លះនៅអមផ្លូវ វានៅជាប់គ្នាទៅ។

ដានី: ធ្វើអីកាលជំនាន់នោះ?

រ៉ន់ៈ ធ្វើស្រែតាៗយើង កើតទាន់តាៗ ។

ដានីៈ ធ្វើស្រែ?

រ៉ន់ៈ បាទ ខ្លះក៏កាប់ចំការ ។

ដានីៈ ធ្វើស្រែ កាប់ចំការ?

រ៉ន់ៈ បាទ ។

ដានីៈ បានហូប ចុក គ្រប់គ្រាន់កាលពីសម័យមុនសង្គ្រាម?

រ៉ន់ៈ បានគ្រប់ខ្លះ អត់ខ្លះ ។

ដានីៈ ក្រៅពីធ្វើស្រែ ធ្វើចំការ គេធ្វើអីទៀត?

រ៉ន់ៈ គ្មានធ្វើអីទៀត គេដងជ័រទឹក កាប់ជ័រចុង ។

ដានីៈ ចុះម្ហូបអីធ្វើម៉េច?

រ៉ន់ៈ ម្ហូបត្រីតាមស្ទឹង អត់មានចេះលក់ ចេះដូរទេលោកក្មួយ ។

ដានីៈ កាលហ្នឹង?

រ៉ន់ៈ បាទ ហើយអ្នកណាបានត្រីអីទាំងវែកគេចែកគ្នាហូបទេពីមុន ។

ដានីៈ មានតែត្រីទេម្ហូប?

រ៉ន់ៈ ត្រី សាច់ព្រៃជ្រូក ។

ដានីៈ សំបូរអត់សាច់ព្រៃ?

រ៉ន់ៈ ជ្រូកសំបូរ ពីដើមសំបូរចំណាប់សត្វភូមិនេះ មានតាំងពីប្រើស ទន្សោង ខ្ទីង គោព្រៃ ច្រើនណាស់ មកបាត់សម័យមុនមក ដែលប៉ុល ពត បាត់អស់ មនុស្សព្រោងព្រាត បាត់អស់ ។

ដានីៈ កាលជំនាន់ប៉ុល ពត បាត់អស់?

រ៉ន់ៈ បាទ មនុស្សនៅពេញដុប កាំភ្លើងទីងទូងៗចេះតែខ្លាចរត់អស់ដឹង ។

ដានីៈ មនុស្សនៅពេញដុប?

រ៉ន់ៈ បាទ ។

ដានីៈ ដុបហ្នឹងព្រៃ?

រ៉ន់ៈ ព្រៃ ។

ដានីៈ អីចឹងទៅជំនាន់ប៉ុល ពត សត្វវាចាប់ផ្ដើមខ្លាច?

រ៉ន់ៈ ខ្លាច វាបាត់អស់រហូតដល់សព្វថ្ងៃ នៅសល់តែឈ្លូស និងជ្រូក ។

ដានីៈ ឥឡូវនៅមានតែឈ្លូស និងជ្រូក?

ភ៉ន់៖ បាទ ។

ដានី៖ ឈ្លូស ហើយនិងជ្រូកនៅណាទៅ?

ភ៉ន់៖ នៅតាមព្រៃឆ្ងាយៗណាស់លោកក្មួយ ប៉ះណាដើរឃើញតែជន្ទុងវា ។

ដានី៖ មកដល់ភូមិដែរ?

ភ៉ន់៖ ដល់ ពីដើមមកសុះ តាមវាលស្រែស៊ីស្រូវហ្នឹង ។

ដានី៖ គេចាប់ម៉េចទៅ?

ភ៉ន់៖ គេបាញ់ (សើច) ។

ដានី៖ គេបាញ់កាំភ្លើង ឬបាញ់ស្នា?

ភ៉ន់៖ កាំភ្លើងពីដើម កាំភ្លើងកាបីន អាច្រកៗបាញ់ទូងមួយគ្រាប់ ។

ដានី៖ កាលហ្នឹងមិនខ្វះទេម្ហូប?

ភ៉ន់៖ មិនខ្វះទេ បើរកវា បើមិនបានរកក៏ខ្វះចុះ មានតាំងពីខ្លានោះនៅនេះ ។

ដានី៖ មានខ្លាទៀត?

ភ៉ន់៖ បាទ នេះដាក់កាំភ្លើងស្ទាយរួម ដាក់ខាងនោះរបៀបកំផែងក្រោលគោ ខាំគោរហូត ខ្លាធំ ។

ដានី៖ កាលជីតាទាន់ពីដើមប្រាសាទកោះកេរ្ដិ៍យ៉ាងម៉េចដែរ?

ភ៉ន់៖ ស្ងាត់ អត់សូវអ្នកណាហ៊ានចូលទេ ខ្លាចសត្វខ្លា បះត្រង់ណាវាកូនតាមកន្ទែងប្រាសាទ ។

ដានី៖ កាលជីតាទាន់ណា ហ្នឹងជីតាទាន់?

ភ៉ន់៖ យូរហើយតាំងពីខ្ញុំនៅក្មេង ជីងតាយាយនាំទៅថាកុំទៅលេងចូលប្រាសាទខ្លាច្រើនណាស់ ។

ដានី៖ ខ្លាច្រើន?

ភ៉ន់៖ បាទ ។

ដានី៖ គេថាក្នុងប្រាសាទមានខ្លាច្រើនអីចឹង?

ភ៉ន់៖ មានកូន ជួនណាវាចូលកូន សុទ្ធតែព្រៃដុបអត់មានស្រឡះបេះទេ ។

ដានី៖ សុទ្ធតែព្រៃអីចឹង?

ភ៉ន់៖ ព្រៃស្រូអីចេះ ចូលទៅបន្តោលជងទេ ។

ដានី៖ តាំងពីជីតាទាន់លោកតានៅក្មេងៗ មុនបួសទៀត?

ភ៉ន់៖ នោះហើយ ស្ងាត់ អត់មានអ្នកណាមករុករើវាអត់ នៅតែស្ងាត់ទេ សត្វច្រើនណាស់ ។

ដានី៖ អត់មានភ្ញៀវទេសចរណ៍មកទេ?

ភ៉ន់៖ អត់ទេ ទើបតែនេះឯង មិនដែលមានទេ ។

ដានី៖ អត់មានពីណាមកអភិវឌ្ឍន៍ទេ?

ព៉ន់: អត់ទេ បើមានពីមុនពេលសម័យឪ សម័យតា មានបារាំងមកខ្លះដែរ ។

ដានី: មានតែបារាំងទេ?

ព៉ន់: មានតែបារាំងមកមើលអីតិចតួចទៅវិញទៅ គេថាបារាំងៗពីដើមក្មេងនោតទើប១៥ឆ្នាំ មិនដឹងណាណីទេ ។

ដានី: អីចឹងតាំងពីជំនាន់តាយាយរបស់លោកពូគាត់និយាយថាបារាំងមក?

ព៉ន់: នោះហើយ ។

ដានី: ដល់ពេលជំនាន់លោកពូអត់ឃើញបារាំងមកទេ?

ព៉ន់: អត់ទេ ដល់ខ្ញុំធំចំណាប់ទៅគេកើតសង្គ្រាមបាត់ទៅហើយ ។

ដានី: ដល់ពេលកើតសង្គ្រាមអត់មានអីទេ?

ព៉ន់: មានអីទៀត នៅកន្ទ្រីង ។

ដានី: នៅតែដុបអីចឹង?

ព៉ន់: នៅតែស្ដុក ។

ដានី: ស្ដុកពេញ?

ព៉ន់: បាទ ខ្លិលណាស់ យ៉ាប់ណាស់ ស្រុកព្រៃអីចេះពិបាកណាស់ ស្រុកមានសង្គ្រាម ។

ដានី: ដល់ពេលបែកខ្មែរក្រហមទៅ ពេលដែលវៀតណាមចូលមកយ៉ាំងម៉េចទៀតទៅស្រុកភូមិយើង?

ព៉ន់: នៅនេះ ។

ដានី: បាទ នៅហ្នឹង?

ព៉ន់: ធ្វើស្រែដដែល ប៉ុលពត ឲ្យធ្វើស្រែរួម ដល់វៀតណាមមកធ្វើស្រែតាមផ្ទះរៀងខ្លួន ដាក់ស្រូវតាមផ្ទះ ។

ដានី: ធ្វើស្រែដាក់តាមផ្ទះ បានយូរទេ?

ព៉ន់: បានយូរហួប ដល់ខ្មែរក្រហមមកក៏ត្រូវដាបត្រដួសមិនបានបាយហូបទេ គោ១១ហើយ ទៅវល់ថាដែរ បាត់អស់ហើយ ។

ដានី: ធ្វើស្រែតាមផ្ទះ ធ្វើបានយូរទេ បានរត់លួនទៀតអត់ពី៧៩មក?

ព៉ន់: ទាល់ប៉ុល ពត ចូលបានឈប់ធ្វើស្រែរៀងខ្លួន ។

ដានី: ប៉ុល ពត ចូលឆ្នាំណាទៀត?

ព៉ន់: ទេ ដែលនិយាយនោះ ។

ដានី: បានន័យថាពេលដែលប៉ុល ពត ចូលមកនេះយើងធ្វើស្រែរួម ហូបបាយរួម ហូបបបរ ដល់ពេលពួកហ្នឹងទៅបាត់អស់ធ្វើម៉េចទៀតទៅ ពួកខ្មែរក្រហមទៅបាត់អស់?

ភ័ន់: ទៅបាត់អស់គ្មានអីទេ ចប់នៅដូចសព្វថ្ងៃអីចឹង ធ្វើស្រែ ។

ដានី: ឈប់មានបាញ់គ្នា?

ភ័ន់: អត់បាញ់ទេ ។

ដានី: អត់មានជម្លៀសទៅណាទៀត?

ភ័ន់: អត់មានជម្លៀស បើថាពី៨៣ភូមិនេះចោលហើយ ។

ដានី: ៨៣ចោល?

ភ័ន់: បាទ ចោលភូមិ ខ្លះទៅនៅខេត្ត ខ្លះទៅនៅគូលែន ព្រោងព្រាតគ្នានោះ ។

ដានី: ចាំមើលឆ្នាំ៨៣ម៉េចបានរត់?

ភ័ន់: ខ្មែរក្រហមវាអុកឡុកដែល៨៣ វៀតណាមក៏នៅនេះចំរុះនោះ មកនៅនេះវៃគ្នាប្រជាជនមិនហ៊ាននៅរត់ ប៉ះត្រង់ណាវាចាប់យកទៅតាមវាទៅភ្នំ ។

ដានី: ពីណាចាប់?

ភ័ន់: ប៉ុល ពត ។

ដានី: ប៉ុល ពត ចាប់?

ភ័ន់: វាកៀរយកទៅឲ្យទៅនៅតាមវាលើភ្នំ ។

ដានី: វៃគ្នាអីចឹង?

ភ័ន់: ៨៣-៨៤-៨៥ បានត្រឡប់មកនៅភូមិនេះវិញ ។

ដានី: អីចឹងលោកពូទៅណាឆ្នាំ៨៣?

ភ័ន់: នៅគូលែន ។

ដានី: អីចឹងឆ្នាំ៨៣រត់ទៅនៅគូលែន?

ភ័ន់: គូលែន នៅខេត្តយើងដែរ ។

ដានី: នៅគូលែន នៅណាទៀតក្រៅពីគូលែន?

ភ័ន់: ចេញពីគូលែននៅប្រដាក ។

ដានី: នៅណា?

ភ័ន់: ភូមិប្រដាក ។

ដានី: ប្រដាកហ្នឹងនៅក្នុងស្រុកអី?

ភ័ន់៖ ស្រុកត្បែង២ ស្រុកគូលែនដែរ គេថាឃុំត្បែង២ ទៅទាំងកូនទាំងប្រពន្ធនៅនោះទាំងអស់ ៨៥ បានមកវិញ មកនៅភូមិនេះវិញ ។

ដានី៖ យើងរត់ទៅខ្លួនឯង ឬវៀតណាមដឹកទៅ?

ភ័ន់៖ អត់ទេរត់ទៅខ្លួនឯង ខ្លាចខ្មែរក្រហម ។

ដានី៖ ខ្លាចខ្មែរក្រហម?

ភ័ន់៖ បាទ បើយើងនៅនេះវាកៀរយកនេះ ដេញប្រជាជនយកទៅលើ ទៅធ្វើការជាមួយវា ធ្វើទាហាន ។

ដានី៖ បើយើងនៅខ្មែរក្រហមកៀរយកទៅ?

ភ័ន់៖ កៀរយកទៅ យើងរត់ខ្លួនយើង យើងដឹងខ្លួនរត់ទៅ នាំកូន នាំប្រពន្ធទៅនៅតាមភូមិគេ រួចគ្នាទៅ វាអត់ហ៊ានចូលទៅដល់ទេនោះឆ្ងាយ ។

ដានី៖ កាលហ្នឹងលោកពូទៅនៅគូលែនហ្នឹងអ្នកភូមិទៅទាំងអស់ ឬមានអ្នកខ្លះទៅជាមួយខ្មែរក្រហម អ្នកខ្លះទៅ?

ភ័ន់៖ ទៅនេះខ្លះៗតាមចិត្តគេ ដែលចេញមិនទាន់ ។

ដានី៖ ទៅគូលែនប្រហែលជាប៉ុន្មានគ្រួសារ ហើយទៅជាខ្មែរក្រហមប្រហែលប៉ុន្មាន?

ភ័ន់៖ មិនដឹងប៉ុន្មានទេលោកក្មួយ វាមិនបានគិតពីដើម ។

ដានី៖ ទៅគូលែនច្រើនជាង ឬទៅជាមួយខ្មែរក្រហមច្រើនជាង?

ភ័ន់៖ ទៅខាងនេះក៏ច្រើន ទៅខាងនោះក៏ច្រើន ទៅប្រហែលពាក់កណ្ដាលគ្នា ។

ដានី៖ ពាក់កណ្ដាលម្នាក់?

ភ័ន់៖ ខ្លះក៏ទៅមិនទាន់ ខ្លះជិះរទេះ ខ្លះគោ ក៏បានវាចូលមកដេញទៅនេះ ខ្លះគ្នាមានរទេះគោដឹក ប្រពន្ធកូនទៅនេះ ប៉ះណាគេនៅគូលែន ប៉ះណារហូតដល់ខេត្តក៏មាន ទៅនោះអត់បាយ អត់ទឹកយើងបែកថ្មី ស៊ីឈ្នួលគេមួយសារនោះស្រុកនេះ ទៅកាប់ចំការស្រែដឹកដីឲ្យគេ យកបាយហូប គេនៅភូមិចាស់គេប្រើ គេជួលឲ្យយើងគាស់ដីឲ្យគេ ចេះតែគាស់អត់បាយ ដែលយើងពីនេះថ្មីទៅនៅភូមិគេ ។

ដានី៖ ឆ្នាំ៨៣ទៅ ឆ្នាំប៉ែតប៉ុន្មានណាត្រឡប់មកវិញ?

ភ័ន់៖ ៨៥មកវិញ ។

ដានី៖ ម៉េចបានត្រឡប់មកវិញ?

ភ័ន់៖ ចុះចប់អត់មានអីទៀតទេ អានោះគេចង់សំរុះនេះហើយ សំរួលស្រួលគ្នាអស់ហើយបាន មកវិញបាននៅជាប់លុះសព្វថ្ងៃ ។

ដានីៈ ឆ្នាំ៨៥ត្រឡប់មកវិញ គេឈប់វ៉ៃគ្នា?

រ៉ាន់ៈ អត់ទេ ៨៥នៅរអាក់រអួលដែរ មិនទាន់ផ្ដាច់ខ្លួនសំរុះសំរួលគ្នាណា នៅកំពុងប្រគេកប្រគាកដែរ ខ្លះមកមិនច្រើនដែរភូមិនេះ ខ្លះមក២-៣គ្រួសារទេមកនៅព្រៃដុប ខ្លះក៏មក ខ្លះនៅមិនទាន់មក គេស្ដាប់ស្រួលបានគេមក មិនកំណត់គ្នា ។

ដានីៈ ពេលមកហ្នឹងខ្មែរក្រហមឈប់ចូលមក?

រ៉ាន់ៈ ដល់មកខ្មែរក្រហមឈប់អស់ គេផ្ដាច់ខ្លួនបណ្ដោយមួយសារនោះ មួយហឹកគេថាស្អីនោះ ដែលខ្មែរក្រហមនិងទាហានឈប់វ៉ៃគ្នា បានមកនៅនេះ ។

ដានីៈ ដល់ពេលមកគេឈប់វ៉ៃគ្នាក្នុងភូមិឈប់ហើយ?

រ៉ាន់ៈ ឈប់ហើយ ។

ដានីៈ ខ្មែរក្រហមក៏ឈប់ចូលមកដែរ?

រ៉ាន់ៈ ឈប់ចូលដែរ ។

ដានីៈ អីចឹងពី៨៥មកនៅស្រួលរហូតឬអត់ទេ?

រ៉ាន់ៈ ពី៨៥មករហូត ខ្លះក៏មក៨៥ ខ្លះក៏៨៦ទៅ វាមិនកំណត់បាន ខ្លះនៅយូរ ។

ដានីៈ វៀតណាមក៏ដកចេញអស់ដែរ?

រ៉ាន់ៈ ដកចេញហើយ ។

ដានីៈ ខ្មែរក្រហមក៏ឈប់ចូលមកសុំមាន់ សុំអង្ករ?

រ៉ាន់ៈ ឈប់ហើយ ។

ដានីៈ ៨៨អីមានខ្មែរក្រហមចូលមកទៀតអត់?

រ៉ាន់ៈ ៨៨មិនមានទេ ។

ដានីៈ អស់ហើយ?

រ៉ាន់ៈ អស់ហើយ មិនដែលបានឃើញចូលមកទៀតទេ ។

ដានីៈ ប្រាសាទអីគ្មានពីណាមកមើល មកប៉ះពាល់? ទៅជាព្រៃស្តុក?

រ៉ាន់ៈ ព្រៃស្តុកអត់មានពីណាមកប៉ះពាល់ទេ ។

ដានីៈ ហើយឆ្នាំណាគេសមាហរណកម្ម?

រ៉ាន់ៈ អើ! ឆ្នាំនោះហើយបានផ្ដាច់ខ្លួនឈប់មានខ្មែរក្រហម ។

ដានីៈ ឆ្នាំ៩៨-៩៩ហើយហ្នឹង?

រ៉ាន់ៈ ទេ ។

ដានីៈ ពីព្រោះឆ្នាំ៩៨-៩៩ខាងអន្លង់វែងគេផ្ដាច់ខ្លួន?

ពីន់ៈ ហ្នឹងអត់សួរចូលមកនេះទេ មិនទាន់ផ្តាច់ក៏វាមិនសួរហ៊ានមក ។

ដានីៈ គេអត់សួរហ៊ានមកដែរ?

ពីន់ៈ នៅដោយកន្ទែងនោះទេ តាមមុខសញ្ញាវានោះទេ ។

ដានីៈ តែលោកពូត្រឡប់មកតាំងពីឆ្នាំ៨៥?

ពីន់ៈ ៨៥ បានខ្ញុំមកនៅលុះសព្វថ្ងៃនេះ ។

ដានីៈ នៅស្រុកភូមិយើងមានមីនដែរ?

ពីន់ៈ មាន ស៊ីម៉ាក់ភាវនោះបានអស់ ។

ដានីៈ អីចឹងកាលមីនពីណាអ្នកដាក់?

ពីន់ៈ ប៉ុល ពត ហើយដាក់នោះ ប៉ុល ពតផង នៅចំរុះ វៀតណាមនៅតាមនេះ ។

ដានីៈ វៀតណាមនៅតាមហ្នឹង?

ពីន់ៈ នេះតាមផ្ទះ ដី ខ្សែលីញវានៅ ប្រជាជននៅចេះ វៀតណាមនៅនេះ ខ្លះនៅតាមព្រៃឯប្រាសាទ ។

ដានីៈ នៅប្រាសាទ?

ពីន់ៈ បាទ នេះគ្រាប់គ្រង់នេះវាដាក់ឃ្លាំង ប៉ុល ពត ចូលបានបែកគ្នា ។

ដានីៈ វ៉ៃឃ្លាំងគ្រាប់វៀតណាម?

ពីន់ៈ បាទ ដាក់ក្នុងប្រាសាទ គ្រាប់ពេញប្រាសាទ ប៉ុល ពត ចូលមកវ៉ៃបែកចំណាប់ ផ្ទុះគ្រាប់ឡើងប៉ុន្មានថ្ងៃ ភឹង១គ្រាប់ហ្នឹង មនុស្សរត់ព្រោងព្រាតបែកគ្នី បែកគ្នា បាត់ឯង បាត់អញអស់ ។

ដានីៈ រត់ពេលហ្នឹងតែម្តង? រត់ឆ្នាំ៨៣ហ្នឹង?

ពីន់ៈ ហ្នឹងហើយ ។

ដានីៈ ៨៣ ពេល ប៉ុល ពត រត់ចូលមកដុតឃ្លាំងហ្នឹង?

ពីន់ៈ ចូលមកវ៉ៃនេះសុទ្ធតែព្រៃចេះឯង យប់ឡើងមិនទាន់ច្បាស់ហ្នឹងវាវ៉ៃ រត់ដឹងណា ដឹងណីយូរក៏វៀតណាមដកទៅនៅស្រយ៉ង់ ក៏មានអីប្រជាជន វាដេញប្រជាជនយកទៅនេះ ខ្លះគេចទៅនេះ គ្នាខ្លះអីក៏ដេញបានទៅនេះ ដូចខ្ញុំថាម៉ិញ ។

ដានីៈ ខ្មែរក្រហមវាដេញយកទៅ?

ពីន់ៈ វាដេញទៅទាញយកកំលាំងប្រើដែរ ។

ដានីៈ ខ្មែរក្រហមខាងណា? ពួកខាងណា?

ពីន់ៈ ខាងមួយជួរអន្លង់វែងនេះឯង ។

ដានី៖ ពីណាប្រធាន?

រ៉ាន់៖ មិនដឹងពីណាពីណី បើប្រធានពីមុនខស្សាហ៍ឃើញ តាហឿង យើងនេះ ។

ដានី៖ តាហឿង?

រ៉ាន់៖ អ៊ើ! ដែលចូលមកនេះ ។

ដានី៖ តាហឿង គាត់ចូលមក?

រ៉ាន់៖ កូនទាហានមិនដែលស្គាល់គេទេ គេថា តាហឿងៗ ។

ដានី៖ តាហឿង ធំជាងគេ?

រ៉ាន់៖ ហ្នឹងឯង ធំជាងគេ ។

ដានី៖ គាត់ចូលមកដល់ហ្នឹងដែរ?

រ៉ាន់៖ ដល់ ដល់ស្រយ៉ង់នោះ ។

ដានី៖ លោកពូដែលឃើញមុខ តាហឿង ទេ?

រ៉ាន់៖ ឃើញ បើឃើញមកស្គាល់ហើយ តែសព្វថ្ងៃចាស់ហើយមិនស្គាល់ទេយ៉ាង គាត់ថានៅសៀមរាបតាំលីគេនិយាយ មកមួយហ៊ឺៗគាត់ដកវិញៗដែរ ។

ដានី៖ មួយហ៊ឺៗដកទៅវិញ?

រ៉ាន់៖ បាទ ។

ដានី៖ អត់ដែលនៅជាប់ទេ?

រ៉ាន់៖ អត់ជាប់ទេ ។

ដានី៖ ដល់មកហ្នឹងយកអីខ្លះទៅ?

រ៉ាន់៖ មករកអង្ករទៅវិញបាត់ ប៉ះណាប៉ះមានវៀតណាមនៅនេះវាអត់ហ៊ានចូលទេ ដល់វៀតណាមដកអស់វាចូល បើនេះចូលខាងនោះចូលមកខាងទាហានខ្មែរយើង ខាងស្រុកនៅភូមិនេះ បានលំបាក ដល់វាចូលមកប៉ះវៃគ្នាក្តុងក្តាំងទៅណា ប្រជាជនកូនចៅក៏រញ៉េរញ៉ៃ ។

ដានី៖ កាលហ្នឹងពីណាគេប្រធានភូមិ?

រ៉ាន់៖ ប្រធានភូមិពីមុន តានី ស្លាប់អស់បាត់ហើយ ។

ដានី៖ ពេលឆ្នាំ៨៣បានន័យថាស្រុកភូមិនេះគ្មានមនុស្សរស់នៅទេ?

រ៉ាន់៖ បាទ ។

ដានី៖ ៨៥បានមកវិញ?

រ៉ាន់៖ បាទ ។

ដានី:		៨៥ ពីណាធ្វើប្រធាន?

ពាន់:		ធ្វើប្រធាន ពូពុត នៅស្រយ៉ង់សព្វថ្ងៃ ។

ដានី:		ឥឡូវគាត់នៅស្រយ៉ង់?

ពាន់:		បាទ ។

ដានី:		គាត់ចាស់ហើយ?

ពាន់:		ចាស់ហើយ ។

ដានី:		ដល់ផុតពីពូវុធ មកពីណា?

ពាន់:		ឈប់មកទល់សព្វថ្ងៃទៀតផ្លាស់ប្តូរ អាយួន ស្លាប់បាត់ទៀតហើយ ។

ដានី:		យួន ស្លាប់ទៅបានពីណាបន្ត?

ពាន់:		តទៀតទល់សព្វថ្ងៃអានេះឯង ។

ដានី:		ពូឌឿន?

ពាន់:		បាទ ។

ដានី:		ចាប់ពីពូយួន មកពូឌឿន ។

ពាន់:		អស់បាត់ហើយ ។

ដានី:		ពូឌឿន គាត់ធ្វើបានប៉ុន្មានឆ្នាំហើយ?

ពាន់:		២-៣ឆ្នាំហើយ ។

ដានី:		អីចឹងពេលដែលលោកពូមកវិញឆ្នាំ៨៥តិចដែលទេ អត់ទាន់មានចូលមកច្រើន?

ពាន់:		តិច ។

ដានី:		ឆ្នាំណាដែលចូលមកច្រើន?

ពាន់:		២០០២ ច្រើន ។

ដានី:		មកពីណាមក?

ពាន់:		មកពីនេះខ្លះ ។

ដានី:		ពីណា?

ពាន់:		អ្នកនៅរំចេក មកពី ប៉ុល ពត ខ្លះ មកពីខាងស្រុកតាមភូមិគេខ្លះមកជុំគ្នា មករកដីភូមិវិញ

ដានី:		អីចឹងអ្នកនៅរំចេក អ្នកអី អ្នកខាងប៉ុល ពត?

ពាន់:		បាទ ។

ដានី:		អ្នកនៅជាមួយខាងប៉ុល ពត គេត្រឡប់មកវិញដែរ?

ពាន់:		ត្រឡប់មកវិញ នៅនោះដដែល តែអ្នកកោះកេរ្តិ៍ហ្នឹងឯង ។

ដានី: ត្រឡប់មកនៅកោះកេរ្តិ៍វិញ?

ភ៉ាន់: នៅរំចេក ។

ដានី: ហើយអ្នកដែលរត់ទៅនៅខាងព្រះវិហារក៏មកវិញដែរ?

ភ៉ាន់: នៅនេះវិញ ឥឡូវដាប់នោះច្រើនចំរុះ ។

ដានី: នៅណា?

ភ៉ាន់: នៅរំចេកមានគ្នាច្រើន បាននៅ២០០២មកជុំហើយ ។

ដានី: មកជុំគ្នា ហើយប្រាសាទនេះគេចាប់ផ្តើមចូលមកឆ្នាំណាទៅ?

ភ៉ាន់: ប៉ុន្មានឆ្នាំមិនបានគិត ដែលពួកហ្នឹងមកធ្វើប៉ុន្មានឆ្នាំហើយទេ ។

ដានី: ទើបតែថ្មីៗនេះដែរទេ?

ភ៉ាន់: ពួកអប្សរាមានយូរអី ។

ដានី: ពួកអប្សរានេះទើបតែមកដែលទេ?

ភ៉ាន់: ទើបមកទេ សួរអានោះបានវាដីង វាកត់ប្រធានភូមិគេ ខ្ញុំមិនសូវបានគិតគូរទេ ទើបមក ឥឡូវៗនេះទេ មកបាន៥-៦, ៨៦ ទេមិនមែនទេ ប៉ុន្មានឆ្នាំទេ សួរអានោះបានដឹង មកយូរគ្រាន់ហើយ ។

ដានី: ហើយខាងអប្សរាគេមក គេលើកំពែងអភិវឌ្ឍន៍អីយ៉ាងម៉េចខ្លះទៅ?

ភ៉ាន់: ខ្ញុំមិនសូវឃើញគេធ្វើការអីអភិវឌ្ឍន៍ថា គ្មានអភិវឌ្ឍន៍អី បើប្រជាជនធ្វើស្រែ ឲ្យស្រែចាស់ៗ ឲ្យធ្វើតែអាចាស់ម៉េចបានអីចុះ អត់ឲ្យគាស់កាយថែមថយអីទេ អត់ឲ្យរើរុះព្រៃទៀតទេ ។

ដានី: អត់ឲ្យរាវព្រៃទេ បើមានស្រែចាស់ធ្វើចាស់ហ្នឹងទៅ?

ភ៉ាន់: បាទ អីចុះឯង គេនិយាយតែអីចឹង គេធ្វើការ ។

ដានី: ប៉ះពាល់ប្រជាជនអីម៉េចខ្លះទៅ?

ភ៉ាន់: ប៉ះហ្នឹងហើយ ប្រជាជនគ្នាអត់ គ្នាចេះតែលួចគាស់លួចកាយ ប៉ះទៅគេហាមគេឃាត់ ។

ដានី: ប៉ុន្មានគីឡូគេអភិវឌ្ឍន៍?

ភ៉ាន់: ប៉ុន្មានគីឡូដីនោះ ប៉ុន្មានទេអានោះកត់ ខ្ញុំមិនសូវប៉ុនចំណាំផង រាប់គីឡូដីនៅដល់រំចេកនោះ

ដានី: ដល់រំចេកទៀត?

ភ៉ាន់: បាទ ព្រំប្រទល់គេ ស្រយ៉ង់ អាឡាក់ដែលដាក់ ឃើញបង្គោលដាក់ចោះបង្គោល ។

ដានី: អីចឹងប្រជាជននៅភូមិកោះកេរ្តិ៍នេះ អ្នកណាមានដីចាស់ ស្រែចាស់ គេឲ្យធ្វើ ប៉ុន្តែអត់ឲ្យរុករានទេ ។

ភ៉ន់៖ អត់ឲ្យរុកថ្មីទេ តែបេះតែលួចលោកក្លួយ ។

ដានី៖ យើងលួចធ្វើបានដែរ?

ភ៉ន់៖ លួចតិចៗ បើគេដើរជួបគេហាមយើងទៀតទៅ គេឃាត់ទុកមិនឲ្យធ្វើទេ គេទៅបាត់យើងលួចតិចៗបាន គេធ្វើបា៉ត់ក៏ស្រេច តែគ្នាអត់ក៏អត់ទៅចុះ អ្នកណាមានបាន ។

ដានី៖ អ្នកស្រុកភូមិម៉េចដែរ ដូចថាមានការសប្បាយចិត្ត ឬមិនសូវសប្បាយចិត្តចំពោះការអភិវឌ្ឍន៍របស់ខាងអប្សរា?

ភ៉ន់៖ ឲ្យរឿងសប្បាយមិនសប្បាយទេ មួយៗគេធ្វើស្រែមិនបាន តាមមើលទៅ ។

ដានី៖ ធ្វើស្រែអត់បាន អត់សប្បាយចិត្តទេ?

ភ៉ន់៖ បាទ បានស្រូវបានអង្ករហូបគេសប្បាយហើយ ទៅហាមឃាត់គ្នាធ្វើមិនបាន ធ្វើម៉េចបាន

ដានី៖ តែគេអត់ហាមយើងមានស្រែចាស់?

ភ៉ន់៖ យើងមានស្រែចាស់បាន តែស្រែវាតិច ធ្វើម៉េចបើកូនច្រើនទៀតធ្វើម៉េចគ្រប់ ព្រោះថាមួយហាត់ កន្លះហាត់ធ្វើម៉េចគ្រប់ តែនិយាយដូចខ្ញុំម៉ិញលួចបេះតែបានតិចៗ គេទៅជួបយើងហាមឃាត់យើងទៅ ប៉ុណ្ណោះឯងទេ មិនមែនថាហាមម៉ឹងម៉ាត់ថាមិនឲ្យធ្វើ តែចិត្តគេនិយាយថា មិនឲ្យកាយកាប់រំរុះព្រៃប៉ុណ្ណោះឯង ដល់យើងអ្នកស្រែ អ្នកចំការបេះតែធ្វើតិចៗ គេហាមហើយឈប់ គេឈប់ហាមធ្វើតិចៗបាន បើគេហាមម៉ាត់ណាហ៊ាននោះប្រជាជនរអ៊ូបើមិនឲ្យគាស់ទៀតធ្វើម៉េចបានឆ្អែតកូនច្រើនម្ល៉េះ ហ៊ានថាតែឯង មិនហ៊ាននិយាយទេ គេមិនឲ្យធ្វើ យើងបានអីហូបកូនចៅច្រើនដែរ ស្រែតែមួយកន្លែង ។

ដានី៖ កូនចៅអ្នកស្រុក អ្នកភូមិនេះ ដូចថាអជ្ញាធរគេមកអភិវឌ្ឍន៍ មានភ្ញៀវទេសចរណ៍មកមើលប្រាសាទដែលឥឡូវ?

ភ៉ន់៖ មក ។

ដានី៖ ដល់មកយើងបានទទួលផលអីពីការគេអភិវឌ្ឍន៍? ភ្ញៀវទេសចរណ៍មកយើងអាចបានផលប្រយោជន៍អីខ្លះហើយពីប្រាសាទ?

ភ៉ន់៖ អារឿងប្រជាជនមិនបានទេ បានការងាររដ្ឋ ភ្ញៀវមកមើលតែប្រាសាទប៉ុណ្ណោះឯង ប្រជាជនក៏យើងនៅផ្ទះ ។

ដានី៖ ដូចថាលក់ដូរ ការងារ?

ភ៉ន់៖ លក់ដូរ បានគេអ្នកលក់នៅកន្លែងប្រាសាទ កន្លែងលក់តិច ។

ដានី៖ ដូចថាការងារផ្សេងៗអីទាក់ទងនឹងរឿងថែរក្សា គេមានជួលអ្នកស្រុក អ្នកភូមិយើងទៅធ្វើការងារដែរ?

ភ៉ន់: គេជួលដែរ ជួលកម្មករទៅបោសប្រាសប្រាសាទនេះ ។

ដានី: បានប្រាក់ខែច្រើនដែរ?

ភ៉ន់: បាន១ថ្ងៃ ៨០០០ ។

ដានី: ដូចថាលោកពូជាអ្នកស្រុកភូមិ មានកំណើតកើតជានៅកោះកេរ្តិ៍តាំងពីកំណើត ពូមានសំណូមពរអីខ្លះទាក់ទងនឹងការអភិវឌ្ឍន៍ប្រាសាទ ទាក់ទងនឹងបញ្ហាផ្សេងៗ?

ភ៉ន់: រឿងប្រាសាទខ្ញុំមិនដឹងបានចេះទាក់ទងអីទេពីព្រោះការងាររបស់គេ បើក្នុងភូមិប្រជាជនតាមរដ្ឋអំណាចភូមិឃុំ គេចង់សំណូមពរឲ្យរីកចំរើន មានអណ្តូងទឹក មានផ្លូវថ្នល់ ធ្វើការងារស្រែ ចំការ ធ្វើម៉េចឲ្យអង្គការជួយខាងផ្លូវ អណ្តូងទឹកអីៗ ។

ដានី: ផ្លូវ អណ្តូងទឹក ចុះទាក់ទងរឿងប្រាសាទ ទាក់ទងនឹងភ្ញៀវទេសចរណ៍?

ភ៉ន់: ការងារគេអ្នកធ្វើការអប្សរា មេៗគេបានដឹង យើងប្រជាជនធ្វើម៉េចដឹងទេ ។

ដានី: តែលោកពូគិតថាប្រាសាទហ្នឹងជារបស់អ្នកស្រុក អ្នកភូមិយើង ឬរបស់ពីណា?

ភ៉ន់: ខ្ញុំថារបស់អ្នកស្រុកហើយ អ្នកស្រុកនៅឃើញជាប់មកហើយ របស់ប្រជាជនខ្មែរយើងហើយ ឃើញប៉ុណ្ណេះ ។

ដានី: តែក្នុងចិត្តលោកពូ លោកពូអត់ចង់ដូចថាចង់បានផលប្រយោជន៍អីពីប្រាសាទទេ?

ភ៉ន់: មិនដឹងចង់បានយ៉ាងណាក្មួយ ចង់បានផលប្រយោជន៍ ចង់បាន តែមិនដឹងចង់បានយ៉ាងណា បានឃើញប្រាសាទកេរ្តិ៍ដំណែលពីយាយតា ផលប្រយោជន៍ឃើញទេសចរណ៍គេមកមើលក៏មិនដឹងផលប្រយោជន៍ គាត់ធ្វើការងារយកយ៉ាងណាៗក៏ខ្ញុំមិនដឹងដែរ ។

ដានី: ខាងអាជ្ញាធរអប្សរាគេខស្សាហ៍ចុះមកប្រជុំ ហៅអ្នកស្រុកអ្នកភូមិប្រជុំដែលអត់?

ភ៉ន់: មិនងាយដែលបានសួរប្រជុំទេ ។

ដានី: អត់ទេ?

ភ៉ន់: បាទ គេធ្វើការតែគ្នាគេ ប៉ះត្រង់ណាបានមកម្តងក៏អរទៅយើងប្រជាជន ចុះមកពីសៀមរាប ។

ដានី: ចុះពីសៀមរាបមក?

ភ៉ន់: បាទ នៅខាងសៀមរាប តែអ្នកនៅកន្លែងក៏នៅ តែយើងមិនដែលបានចុះធ្វើការអី ធ្វើការធ្វើងារតាមការងារគេអ្នកធ្វើការនោះ ណែនាំអ្នកដែលដូចថាខ្ញុំទៅស៊ីឈ្នួលគេត្រួសចំការគិចតួចបោសប្រាស គេប្រាប់ខំបោស ខំប្រាស ។

ដានី: លោកពូដូចថាមានដែលលឺព័ត៌មានអីស្តីពីការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមអី?

ភ៉ន់: អត់ដែលបានបើកលឺ ។

ដានីៈ តែដឹងដែរ?

ភ៉ន់ៈ ដឹង លឺគេថាកាត់ទោស ដឹងលឺដែរ ។

ដានីៈ គេកាត់ទោសនៅណា?

ភ៉ន់ៈ នៅត្រង់ណាទេ លឺគេថានោះ ។

ដានីៈ លឺគេថាម៉េច?

ភ៉ន់ៈ កាត់ទោសខ្មែរក្រហម ។

ដានីៈ កាត់ទោសពីណាខ្លះ?

ភ៉ន់ៈ អត់ស្គាល់ឈ្មោះទេ ។

ដានីៈ អត់ស្គាល់ឈ្មោះមេដឹកនាំខ្មែរក្រហម?

ភ៉ន់ៈ អត់ទេ ។

ដានីៈ លឺតែគេថាកាត់ទោសៗ?

ភ៉ន់ៈ កាត់ទោសៗខ្មែរក្រហម ។

ដានីៈ ពូយល់ឃើញម៉េចដែលកាត់ទោសខ្មែរក្រហម?

ភ៉ន់ៈ យល់ឃើញថាវាធ្វើបាបប្រជាជនខ្លាំងពេកត្រូវតែកាត់ទោស (សើច) ។

ដានីៈ លោកពូកាលជំនាន់ហ្នឹងឆ្លងកាត់ កាលពីសម័យខ្មែរក្រហម ដឹងថាពួកខ្មែរក្រហមធ្វើបាប
ប្រជាជន?

ភ៉ន់ៈ ធ្វើហើយ ឃើញធ្វើបាប ។

ដានីៈ ដែលស្គាល់តាម៉ុក ដែរ?

ភ៉ន់ៈ លឺតែឈ្មោះ ។

ដានីៈ ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន អីដែលលឺទេ?

ភ៉ន់ៈ លឺឈ្មោះមែនហើយ តែមិនដែលឃើញរូបរាងទេ ។

ដានីៈ លឺតែឈ្មោះ?

ភ៉ន់ៈ បាទ មិនដែលមកនេះម៉េចបានឃើញ ។

ដានីៈ លោកពូដែលទៅភ្នំពេញដែរ?

ភ៉ន់ៈ ចាស់ប៉ុណ្ណេះមិនដែលស្គាល់ផង ។

ដានីៈ ទៅណា?

ភ៉ន់ៈ មិនដែលទៅឃើញទេ ចាស់ប៉ុណ្ណេះហើយមិនដែលទៅ ។

ដានីៈ ចុះទៅព្រះវិហារ?

ភ័ន់: ព្រះវិហារមិនដែលទៅទៀតនោះណា៎ ។

ដានី: ចុះទីរួមខេត្ត?

ភ័ន់: បើខេត្តយើងទៅ ។

ដានី: ខេត្តព្រះវិហារ?

ភ័ន់: ក្នុងខេត្តទៅ ។

ដានី: បើប្រាសាទព្រះវិហារអត់ដែលទៅ?

ភ័ន់: អត់ដែលទៅទេ បើខេត្តទៅ ។

ដានី: សៀមរាប?

ភ័ន់: សៀមរាបបានទៅដែរ ទៅដល់អង្គរនឹងគេដែរ ។

ដានី: ទៅមើលអង្គរប៉ុន្មានដងហើយ?

ភ័ន់: បាន២ដងហើយ បើទៅឆ្ងាយៗមិនដែលបានទៅ ភ្នំពេញមិនដែលស្គាល់ ។

ដានី: ចុះកូនចៅគាត់នៅធ្វើស្រែចំការនៅហ្នឹង ឬមានទៅធ្វើការឆ្ងាយៗដែរ?

ភ័ន់: អត់ទេនៅធ្វើស្រែ យកប្ដីប្រពន្ធអស់បាត់ហើយ ។

ដានី: យកនៅនេះ?

ភ័ន់: នៅនេះអត់ទេ នៅនេះតែ២នាក់នៅរៀនម្នាក់ ។

ដានី: ផ្សេងៗនៅណា?

ភ័ន់: យកប្រពន្ធនៅប្រដាក ។

ដានី: ប្រដាក នៅខាងគូលែន?

ភ័ន់: ប្រដាក-គូលែន យកប្រពន្ធនៅហ្នឹង នៅនេះតែ២នាក់ទេ ។

ដានី: នៅណាទៀត?

ភ័ន់: នៅប្រដាកទាំងអស់ យកប្រពន្ធនៅនោះ ប្ដីនៅនោះ ។

ដានី: ខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំលោកពូទៀតហើយ អីចឹងលោកពូមានអ៊ីចង់បន្ថែមនៅអ្វីដែលខ្ញុំមិនបានសួរនាំទេ?

ភ័ន់: មិនមានអ៊ីបន្ថែមទេលោកក្មួយ និយាយប៉ុណ្ណេះឯង ។

ដានី: បាទ ខ្ញុំអរគុណលោកពូច្រើន ។

ភ័ន់: បាទ ។

ចប់